# កម្មវិធីជាតិរេដ+កម្ពុជា

គម្រោងUNDPលេខ00078446

(ផ្ទះលេខ៥០ មហាវិថីព្រះនរោតម្ត ខ័ណ្ឌដូនពេញ ភ្នំពេញ កម្ពុជា អគារជាន់ទី៣)

---

## សេចក្តីប្រកាសជ្រើសរើសតំណាងពាក់ព័ន្ធស្ម័គ្រចិត្តដែលមានបទពិសោធន៍ "អ្នកតំណាង ចំនួន ១៨ នាក់ ដើម្បីបង្កើតជាក្រុមពិភាក្សារេដ+"

### I. ពត៌មានទូទៅ

យន្តការទៅអនាគតនៃ រេដ+ (REDD+ មានន័យថា ការកាត់បន្ថយការបំភាយឧស្ម័នពីការកាប់បំផ្លាញព្រៃឈើ និង ការរិចរឹលនៃព្រៃឈើ (Reducing Emission from Deforestation and Forest Degration)) ផ្តល់ឱកាសមួយសម្រាប់ប្រទេសកម្ពុជាក្នុងការបង្កើនលទ្ធភាពក្នុងការការពារ និង ប្រើប្រាស់ព្រៃឈើរបស់ខ្លួនឲ្យមាននិរន្តភាព។

ផែនការសកម្មភាពរបស់ រេដ+ នឹងពិពណ៌នាអំពីមធ្យោបាយដែលប្រទេសកម្ពុជាត្រៀមខ្លួនជាំស្រេចក្នុងការអនុវត្ត រេដ+ និង រាប់បញ្ចូលទាំងសេចក្តីព្រាងនៃផែនការចូលរួម និងពិភាក្សា។ ផែនការនេះនឹងបង្ហាញពីមធ្យោបាយដែលអ្នកពាក់ព័ន្ធនឹងចូលរួមចំណែក ជាពិសេសនៅក្នុងដំណើការនៃ **កម្មវធីជាតិរេដ+កម្ពុជា** (Cambodian National REDD+ process) តាមរយៈការបង្កើតឡើងនូវក្រុមពិភាក្សារេដ+ "REDD+ Consultation Group"។ ក្រុមពិភាក្សានឹងជាក្រុមមួយសម្រាប់បង្ហាញពី ឬផ្តល់ទស្សនៈនៃក្រុមអ្នកពាក់ព័ន្ធខុសៗគ្នា ហើយក៏គាំទ្រក្រុមការងាររេដ+កម្ពុជា (Cambodia REDD+ Taskforce) ក្នុងរូបភាពជាការណែនាំ ឬ ការផ្តល់យោបល់។

**ក្រុមពិភាក្សារេដ+** នឹងមានអ្នកតំណាងចូលរួមចំនួន ១៨ នាក់ ដូចខាងក្រោម៖

- សមាជិក ២រូប មកពី អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក
- សមាជិក ២រូប មកពី អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ
- សមាជិក ២រូប មកពី សង្គមស៊ីវិល
- សមាជិក ២រូប មកពី ក្រុមជនជាតិភាគដើមភាគតិច
- សមាជិក ២រូប មកពី វិស័យឯកជន
- សមាជិក ២រូប មកពី ស្ថាប័នអប់រំ

- សមាជិក ៦រូបៈ ២រូប មកពីតំណាងសហគមន៍ព្រៃឈើ (CF), ២រូប មកពីសហគមន៍ជលផល (CFi), ២រូប មកពីតំបន់ការពារសហគមន៍ (CPA)។

## II. រយៈពេលនៃក្រុមពិភាក្សា

សមាជិកក្រុមពិភាក្សានឹងធ្វើការរយៈពេល ៣ឆ្នាំ ហើយនឹងមានការត្រួតពិនិត្យដំណើការដែលអាចនាំឲ្យមានការជួបប្រជុំនៅពេលក្រោយ។ សមាជិកថ្មីនៃក្រុមពិភាក្សា នឹងត្រូវធ្វើការជ្រើសរើសដោយស្ថាប័នពាក់ព័ន្ធ។

បេក្ខជនដែលមានចំណាប់អារម្មណ៍ សូមបំពេញបែបបទនៅក្នុងទម្រង់បែបបទដែលភ្ជាប់ជាមួយនឹងព័ត៌មានរបស់ស្ថាប័នរបស់ខ្លួន លិខិតបង្ហាញពីចំណាប់អារម្មណ៍ និងលិខិតអនុញ្ញាតយល់ព្រមពីស្ថាប័នរបស់ខ្លួន **នៅត្រឹមថ្ងៃទី ២២ ខែឧសភា ឆ្នាំ២០១៣** ដោយផ្ញើរមកកាន់អ៊ីម៉ែល redd.secretariat@cambodia-redd.org ។

ការផ្តល់ព័តមាននឹងប្រព្រឹត្តទៅនៅថ្ងៃទី៨ ខែឧសភា ឆ្នាំ២០១៣ នៅម៉ោង១៥.០០ នៅបន្ទប់ប្រជុំរដ្ឋបាលព្រៃឈើជាន់ទី ១

**សម្រាប់ព័តមានបន្ថែម និងការស្នើសុំឯកសារពាក់ព័ន្ធ ក៏ដូចជា ទម្រង់បែបបទ និងលក្ខខណ្ឌការងារ សូមទាក់ទងមកៈ**

លេខសទូរស័ព្ទៈ +៨៥៥ ១២ ៦៣៨ ៨៧០ / ១២ ៥០០ ៩២២

អ៊ីម៉ែលៈ redd.secretariat@cambodia-redd.org